# ក្របខ័ណ្ឌសម្រាប់វិមជ្ឈការ

Eddie Dorotan, MD, MPA

ទីក្រុងភ្នំពេញ  កម្ពុជា

ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ ២០០៨

# យល់ដឹងពីមូលហេតុដែលអ្នកចង់ឱ្យមានវិមជ្ឈការ

- វិមជ្ឈការភាគច្រើនដែលកើតមាននៅក្នុងទសវត្សរ៍កន្លងមក គឺដោយសារកង្វល់ផ្នែកនយោបាយ ។
- **ប្រទេសអាមេរិកឡាទីនៈ** វិមជ្ឈការបានក្លាយជាផ្នែកយ៉ាងសំខាន់នៃដំណើរការ**ប្ដូរទៅជាលិទ្ធិប្រជាធិបតេយ្យ** នៅពេលដែលរបបផ្ដាច់ការត្រូវបានជំនួសដោយរដ្ឋាភិបាលដែលមានការជ្រើសរើសនិងមានរដ្ឋធម្មនុញ្ញថ្មីៗ ។
- **ប្រទេសអាហ្វ្រិកៈ** ការរីកសាយភាយនៃប្រព័ន្ធនយោបាយបែបពហុបក្ស គឺតម្រូវឱ្យមានសំឡេងពីប្រជាពលរដ្ឋតាមមូលដ្ឋានក្នុងការធ្វើសេចក្ដីសម្រេចចិត្តនានា ។
- **ប្រទេសអេស្ប៉ាញៈ** វិមជ្ឈការកើតឡើងដោយសារមានសម្ពាធពីក្រុមជនជាតិភាគតិចនិងប្រជាពលរដ្ឋនៅក្នុងតំបន់ ទាមទារឱ្យពួកគាត់អាចគ្រប់គ្រង ឬ ចូលរួមនៅក្នុងដំណើរការនយោបាយ ។ នៅក្នុងន័យមួយទៀត វិមជ្ឈការ តំណាងឱ្យការព្យាយាមយ៉ាងខ្លាំងក្នុងការរួបរួមប្រទេសជាតិដើម្បីប្រឈមមុខនឹងសម្ពាធទាំងនេះ ដោយផ្ដល់នូវស្វយ័តភាពបន្ថែមទៅឱ្យអាជ្ញាធរមូលដ្ឋាន ឬ ទៅឱ្យប្រជាពលរដ្ឋនៅក្នុងតំបន់ ដោយបង្កើតឡើងនូវ "សហព័ន្ធដែលមិនស្មើគ្នា" ។

# យល់ដឹងពីមូលហេតុដែលអ្នកចង់ឱ្យមានវិមជ្ឈការ

- វិមជ្ឈការគឺជា**លទ្ធផលមួយនៃសង្គ្រាមស៊ីវិលដែលអូសបន្លាយយ៉ាងយូរ** ដូចជាសង្គ្រាមនៅក្នុង**ប្រទេសម៉ូសំប៊ិច ប្រទេសអ៊ូកង់ដា** ដែលនៅទីនោះការបើកឱ្យមានឱកាសនយោបាយនៅតាមថ្នាក់មូលដ្ឋានបានអនុញ្ញាតឱ្យមានការចូលរួមយ៉ាងខ្លាំងពីអតីតក្រុមជម្លោះផ្សេងៗក្នុងការគ្រប់គ្រងប្រទេស ។
- **សេដ្ឋកិច្ចអន្តរកាល**នៃ**រដ្ឋអតីតសង្គមនិយម** ក៏បានធ្វើការផ្ទេរអំណាចយ៉ាងច្រើននៅពេលដែលអំណាចកណ្តាលសម័យមុនត្រូវបានដួលរលំ ។ ក្នុងប្រទេសជាច្រើន វិមជ្ឈការ**ត្រូវបានបង្កើតឡើងដោយមិនមានរចនាសម្ព័ន្ធអភិបាលកិច្ច** ដើម្បីផ្តល់សេវានានាទៅកាន់រដ្ឋបាលមូលដ្ឋាន ។
- **វិមជ្ឈការនៅអាស៊ីបូព៌ា** ចាប់ផ្តើមកើតមានដោយសារមាន**តម្រូវការក្នុងការចែកចាយសេវាទៅកាន់ប្រជាជនដែលមានចំនួនច្រើន** និងការទទួលស្គាល់នូវកម្រិតរបស់រដ្ឋបាលថ្នាក់កណ្តាល ។

# ការសិក្សាពីផលប៉ះពាល់នៃវិបត្តិការ

- ថ្វីបើហេតុផលជាចម្បងចំពោះវិបត្តិការនៅជុំវិញពិភពលោកដែលថា វាគឺកើតឡើងបែបសាមញ្ញក៏ដោយ  ក៏វាមាន**បញ្ហាកើតមានយ៉ាងច្រើន**ដែរដែលជះឥទ្ធិពល ទៅដល់វិបត្តិការដែលមានប្រភេទខុសៗគ្នា នៃ**ប្រសិទ្ធផល  សមភាព និងម៉ាក្រូស្ថេរភាពដែរ**។

# ការសិក្សាពីផលប៉ះពាល់នៃវិមជ្ឈការ

## ប្រសិទ្ធភាពនៃការធ្វើសេចក្ដីសម្រេច

- មូលហេតុគឺថាសេចក្ដីសម្រេចអំពីការចំណាយសាធារណៈដែលចំណាយដោយរដ្ឋាភិបាលនៅកម្រិតណាមួយដែលនៅជិតនឹងប្រជាពលរដ្ឋ គឺអាចឆ្លើយតបទៅនឹង **តម្រូវការសេវានានារបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន** ច្រើនជាងការ សម្រេចដែលធ្វើឡើងដោយរដ្ឋបាលថ្នាក់កណ្ដាល ។
- ប្រជាជន**មានទំនោរកើនឡើងក្នុងការចំណាយ**សម្រាប់សេវានានា ដែលឆ្លើយតបទៅនឹងអាទិភាពរបស់គាត់ ជាពិសេសប្រសិនបើពួកគាត់បានចូលរួមក្នុងដំណើរនៃការធ្វើសេចក្ដីសម្រេចទាក់ទងទៅនឹងការផ្ដល់នូវសេវាកម្មនានា ។
- លើកកម្ពស់ "**ការប្រកួតប្រជែង**" នៃរដ្ឋបាល និងពង្រីក**ការច្នៃប្រឌិត**--ដើម្បីឱ្យពួកគាត់ធ្វើសកម្មភាពដើម្បីបំពេញបំណងប្រាថ្នារបស់ប្រជាពលរដ្ឋ ។

# ការសិក្សាពីផលប៉ះពាល់នៃវិបត្តិការ

## ស្ថេរភាពម៉ាក្រូ

- វិបត្តិការអាចធ្វើឱ្យ ការអនុវត្តគោលនយោបាយស្ថេរភាព កាន់តែពិបាក ហើយអាចធ្វើឱ្យមានអស្ថេរភាពទៅដល់សមាសភាពនៃការចំណាយ និងបំណុលសាធារណៈទូទៅ។
- តែទោះជាយ៉ាងណាក៏ដោយ ទស្សនវិស័យមួយទៀតនៃគោលនយោបាយនេះ គឺថាប្រព័ន្ធដែលបានធ្វើការផ្ទេរសិទ្ធិអំណាចអាចត្រូវបានកែច្នៃដើម្បីជៀសវាងផលប៉ះពាល់អស្ថេរភាព ហើយធានានូវការលើកទឹកចិត្តដែលត្រឹមត្រូវ។ ឧទាហរណ៍ "វិបត្តិការ" មួយចំនួនក្នុងអំឡុងឆ្នាំ១៩៨0 រដ្ឋាភិបាលកណ្តាល និងថ្នាក់បន្តបន្ទាប់មិនបានទទួលរ៉ែកពុនបន្ទុកនូវអតុល្យភាពសារពើពន្ធឡើយ។ នៅក្នុងកាលៈទេសៈបែបនេះ វាមិនគួរភ្ញាក់ផ្អើលទេដែលមើលឃើញនូវទំនាក់ទំនងយ៉ាងខ្លាំងក្លារមួយវាងវិបត្តិការ និងសារពើពន្ធនៅតាមថ្នាក់ក្រោម ។
- មានបញ្ហាជម្រោងចម្រាសក្នុងកម្រិតទ្រង់ទ្រាយធំមួយផ្សេងទៀតគឺថាមានភស្តុតាងមិនច្បាស់លាស់ដែលថាវិបត្តិការធ្វើឱ្យឃឹតយ៉ាវដល់ **ការលូតលាស់សេដ្ឋកិច្ច** ពិតមែនឬយ៉ាងណា។

# ការសិក្សាពីផលប៉ះពាល់នៃវិមជ្ឈការ

**សមភាព**

- យុត្តាធិការមួយចំនួនដែលមានធនធានផ្តល់ឱ្យគ្រប់គ្រាន់មានលក្ខណៈល្អប្រសើរជាង រឿងផ្សេងទៀត នេះអាចដោយសារតែពីទំហំ ឬ ទីតាំង ។
- កម្មវិធីសារពើពន្ធរបស់អន្តររដ្ឋាភិបាលអាចបង្កើតឡើងដើម្បី**ផ្លាស់ប្តូរបង្វែធនធានទៅកាន់តំបន់ដែលខ្សត់ខ្សោយ** ដើម្បីធានាថា ប្រជាពលរដ្ឋគ្រប់រូបរីករាយជាមួយនឹងសេវាកម្មក្នុងកម្រិតអប្បរមាដោយមិនគិតពីទីតាំង ឬ ទទួលជំនួយបន្ថែមដើម្បីបង្កើនការធ្វើឱ្យប្រសើរឡើងនូវការខូចខាតដោយសារតែតំបន់ទីតាំង ។
- **ការសម្រេចនៃការផ្តល់ជំនួយដល់កម្មវិធីក្រីក្រ**ទៅដល់ថ្នាក់ក្រោមដែលទាបជាងកម្រិតជាតិនោះគួរត្រូវវិភាគនៅក្នុងបរិបទនៃប្រទេសនោះ ដោយសារថាភាពខ្សត់ខ្សោយនៃតម្លាភាព ឬភាពមិនជាក់ លាក់ក្នុងការផ្ទេរ ពេលខ្លះបណ្តាលឱ្យតំបន់ដែលមានព្រទ្យធនច្រើនទទួលបានធនធានច្រើនជាងតំបន់ដែលក្រីក្រជាង ។

# លក្ខណៈសំខាន់ៗចំនួន៥សម្រាប់វិមជ្ឈការដែលជោគជ័យ

- ទោះបីជា **នយោបាយ** គឺជាកម្លាំងដឹកនាំដែលនៅពីក្រោយវិមជ្ឈការនៅក្នុងប្រទេសជាច្រើនក៏ដោយ  ក៏វិមជ្ឈការប្រហែលជាឧទាហរណ៍មួយក្នុងចំណោមករណីទាំងឡាយនោះ ដែលថា **នយោបាយនិងសេដ្ឋកិច្ចល្អ អាចជួយឱ្យបានដល់ទីបញ្ចប់ដូចគ្នា។**
- គោលដៅខាងនយោបាយដើម្បីបង្កើន ការឆ្លើយតបនិងការចូលរួមខាងនយោបាយនៅកម្រិតមូលដ្ឋាន   អាចកើតឡើងដំណាលគ្នានឹងគោលដៅនៃការសម្រេចចិត្តផ្នែកសេដ្ឋកិច្ច អំពីការប្រើប្រាស់ធនធានសាធារណៈ ដែលប្រសើរជាង និងបង្កើនការស្ម័គ្រចិត្តបង់ថ្លៃសេវាកម្មតាមមូលដ្ឋាន ។

# លក្ខខណ្ឌសំខាន់ៗចំនួន៥សម្រាប់វិមជ្ឈការដែលជោគជ័យ

1. ក្របខ័ណ្ឌវិមជ្ឈការ **ត្រូវតែភ្ជាប់ហិរញ្ញប្បទាន និងសារពើពន្ធ ទៅនឹង**ទំនួលខុសត្រូវនៃ**ការផ្តល់នូវសេវាកម្ម** និងមុខងាររដ្ឋបាលតាមមូលដ្ឋាន ដើម្បីឱ្យអ្នកនយោបាយតាមមូលដ្ឋានអាចទ្រទ្រង់ការចំណាយដែលពួកគាត់បានសម្រេច និងអាចបំពេញការងារទៅតាមអ្វីដែលពួកគាត់បានសន្យា។

2. ត្រូវជូនដំណឹងទៅសហគមន៍តាមមូលដ្ឋាន **អំពីតម្លៃនៃសេវានានា និងជម្រើសនៃការចែកចាយសេវាកម្ម** ដែលពាក់ពន្ធ័ និងការគ្រប់ដណ្តប់នៃធនធាន និងប្រភពរបស់វា។ ដូចនេះសេចក្តីសម្រេចដែលគេធ្វើឡើងគឺមានប្រយោជន៍។ **គម្រោងថវិកាសម្រាប់ចូលរួម** ដូចជា Porto Alegre, Brazil គឺជាមធ្យោបាយមួយដើម្បីបង្កើតលក្ខខណ្ឌនេះ។

# លក្ខខណ្ឌសំខាន់ៗចំនួន៥សម្រាប់វិមជ្ឈការដែលជោគជ័យ

៣. ត្រូវមានយន្តការមួយដែល **សហគមន៍អាចបង្ហាញពីចំណូលចិត្តរបស់ខ្លួន** នៅក្រោមរូបភាពដែលមានការពាក់ពន្ធ័ជាមួយនឹងអ្នកនយោបាយ ដូចនេះវាមានការលើកទឹកចិត្តឱ្យមនុស្សចូលរួម

៤. ត្រូវមានប្រព័ន្ធ **គណនេយ្យភាព**ដែលពឹងផ្អែកទៅលើ**ព័ត៌មានសាធារណៈ និងមានតម្លាភាព** ដែលជួយដល់សហគមន៍ឱ្យ**ត្រួតពិនិត្យតាមដានការអនុវត្ត**នៃរដ្ឋបាលតាមមូលដ្ឋានឱ្យមានប្រសិទ្ធភាព ហើយឆ្លើយតបយ៉ាងសមស្របទៅនឹងការអនុវត្តនោះ ដូចនេះអ្នកនយោបាយ និងមន្ត្រីតាមមូលដ្ឋាននឹងមានការលើកទឹកចិត្តដើម្បីធ្វើការឆ្លើយតប ។

# លក្ខខណ្ឌសំខាន់ៗចំនួន៥សម្រាប់វិមជ្ឈការដែលជោគជ័យ

៥. ឧបករណ៍វិមជ្ឈការ-- **ក្របខ័ណ្ឌច្បាប់ និងស្ថាប័ន**

ទំនួលខុសត្រូវនៃការចែកចាយសេវា និងប្រព័ន្ធសារពើពន្ធរបស់រដ្ឋាភិបាល --ត្រូវបង្កើតឡើងដើម្បីគាំទ្រដល់គោលបំណងនយោបាយ ។

# លក្ខខណ្ឌសំខាន់ៗចំនួន៥សម្រាប់វិមជ្ឈការដែលជោគជ័យ

- ការសំរេចបាននូវគោលដៅទាំងអស់នេះគឺជាបទបញ្ហាយ៉ាងខ្ពស់ តែយើងអាចសម្រេចបាន។
- វិមជ្ឈការដែលជោគជ័យគឺទាក់ទងយ៉ាងជិតស្និទទៅនឹងការសង្កេតមើលគោលការណ៍ដែលបានបង្កើតឡើងនៃ ៖ មុខងារតាមដានហិរញ្ញវត្ថុ  ការធ្វើសេចក្ដីសម្រេចជូនដំណឹងប្រកាន់យកគោលការណ៍អាទិភាពតាមមូលដ្ឋាន  និងគណនេយ្យភាព។
- ប៉ុន្តែការអនុវត្តគោលការណ៍ទាំងនេះនៅក្នុងភាពជាក់ស្តែង គឺមិនងាយស្រួលនោះទេ។ ភាពខុសគ្នានៃកាលៈទេសៈនៅក្នុងប្រទេស ជាលក្ខណៈពិបាកយល់ និងស្មុគស្មាញ ហើយដែលទាមទារឱ្យមានការបង្កើតឡើងនូវវិមជ្ឈការដែលសមស្របទៅតាម ប្រទេសរៀងៗខ្លួន។

# ឧទាហរណ៍អំពីប្រទេសមួយចំនួនដែលប្រើវិមជ្ឈការ

- ប្រទេស ហ្វីលីពីន
- ប្រទេស អាហ្វ្រិក
- ប្រទេសអាមេរិកឡាទីន

# ប្រទេសហ្វីលីពីន

- មានប្រជាជនចំនួន ៨៤លាននាក់ មានកោះ ចំនួន ៧១00កោះ
- ច្បាប់រដ្ឋបាលមូលដ្ឋានឆ្នាំ ១៩៩១
- រដ្ឋាភិបាលបែបប្រធានាធិបតីដែលមានស្ថាប័នបីស្មើគ្នា
  (នីតិប្រតិបត្តិ  នីតិបញ្ញត្តិ តុលាការ)
- មានខេត្តចំនួន៧៩  ទីក្រុងចំនួន១២៥  ក្រុងចំនួន១៥00  Barangays
  ចំនួន៤២ 000

# ពីមុខងារអភិវឌ្ឍ  ទៅជាមុខងាររដ្ឋបាលតាមមូលដ្ឋាន

- វិសាលភាពនៃវិស័យកសិកម្ម និងនេសាទ
- កម្មវិធីរុក្ខាប្រមាញ់សម្រាប់សហគមន៍តាមមូលដ្ឋាន
- សេវាថែទាំសុខភាព ( មណ្ឌលសុខភាពតាមជនបទ និងមន្ទីរពេទ្យស្រុក/ខេត្ត)
- សេវាកម្មសុខុមាលភាពសង្គម

# តួនាទីនៃអង្គការមហាជន
# និងអង្គការក្រៅរដ្ឋាភិបាលនៅក្នុងកិច្ចការរដ្ឋបាលមូលដ្ឋាន

- ស្ថាប័នពិសេសតាមមូលដ្ឋាន
- ការចែកចាយសេវាកម្មនានាតាមមូលដ្ឋាន
- គម្រោងរួមគ្នា និងកម្មវិធីសហប្រតិបត្តិការ
- បែបបទហិរញ្ញវត្ថុ និងបែបបទផ្សេងៗទៀតនៃជំនួយ
- ការប្រព្រឹត្តជាទីពេញចិត្តចំពោះអង្គការនិងសហករណ៍អ្នកនេសាទតូចតាចទាំងឡាយ
- ការប្រព្រឹត្តជាទីគាប់ចិត្តចំពោះការអភិវឌ្ឍសហករណ៍
- ការផ្តល់ហិរញ្ញប្បទាន  ការសាងសង់  ការថែទាំ  ប្រតិបត្តិការ និងការគ្រប់គ្រង គម្រោងហេដ្ឋារចនាសម្ព័ន្ធនានា

# ស្ថាប័នពិសេសៗតាមមូលដ្ឋាន

- ក្រុមប្រឹក្សាអភិវឌ្ឍមូលដ្ឋាន ( អង្គការក្រៅរដ្ឋាភិបាល ១/៤)
- ការផ្តល់សិទ្ធិជាមុន ការដេញថ្លៃ និងគណៈកម្មាធិការផ្តល់រង្វាន់នៅតាមមូលដ្ឋាន
- ក្រុមប្រឹក្សាសុខាភិបាលថ្នាក់មូលដ្ឋាន
- ក្រុមប្រឹក្សាសាលារៀនថ្នាក់មូលដ្ឋាន
- ក្រុមប្រឹក្សាសន្តិសុខ និងសណ្តាប់ធ្នាប់តាមមូលដ្ឋាន
- ក្រុមប្រឹក្សាពង្រឹងការអនុវត្តច្បាប់របស់ប្រជាជន

# បញ្ហាកើតមានមួយចំនួន

- ការផ្ទេរមុខងារមិនត្រូវបានគាំទ្រឱ្យបានពេញលេញផ្នែកធនធានហិរញ្ញវត្ថុ
- ស្ថាប័នពិសេសៗតាមមូលដ្ឋាន មិនមានប្រតិបត្តិការពេញទំហឹងប៉ុន្តែ នៅក្នុងតំបន់ដែលគេប្រតិបត្តិការបានល្អ គឺនៅក្នុងតំបន់ដែលមានអភិបាលកិច្ចល្អស្រាប់ហើយ ។
- តម្លាភាព និងគណនេយ្យភាពនៅតែមានភាពខ្សត់ខ្សោយ
- វិសមភាពហិរញ្ញវត្ថុក្នុងចំណោមផ្នែករដ្ឋបាលតាមមូលដ្ឋាននានា
- តំបន់ស្វយ័តនៅក្នុង Mindanao នៅតែទាមទារឱ្យមានអភិបាលកិច្ចល្អ